**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

## សេចក្តីប្រកាសព័ត៌មាន

## លទ្ធផល នៃជំនួបរវាង ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង ឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំនៅកម្ពុជា និងលោក Emmanuel Dollfus នាយករង នៃទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ប្រចាំប្រទេសកម្ពុជា

ភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ – **ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** បានអនុញ្ញាតឱ្យ **ឯកឧត្តម** Jacques Pellet **ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំប្រទេសកម្ពុជា** និងលោក Emmanuel Dollfus នាយករង នៃទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ប្រចាំប្រទេសកម្ពុជា(AFD) ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារអំពីសក្តានុពលដើម្បីជំរុញកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍។

នាឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម ឯកអគ្គរដ្ឋទូត និង តំណាង AFD បានបង្ហាញពីការអរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលបារាំង ដែលរួមមាន AFD ដែលតែងតែផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អកន្លងមក និងបន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ជាពិសេសការជួយដល់គម្រោងបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ (VST) នៅរាជធានីភ្នំពេញ និងខេត្ត ព្រះសីហនុ ព្រមទាំងកម្មវិធីពង្រឹងសមត្ថភាពពាណិជ្ជកម្មក្នុងវិស័យទេសចរណ៍ (Tourism Commercial Capacity Building Programme – TCBP) ផងដែរ។ ជាចក្ខុវិស័យសម្រាប់អាណត្តិទី៧ថ្មីរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងទេសចរណ៍បានដាក់ចេញនូវគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រ "**បង្កើន៥-BUILD**" និង "**អភិវឌ្ឍ៣-3Ds**" សំដៅជំរុញស្ទួយ និងអភិវឌ្ឍវិស័យទេសចរណ៍ប្រែក្លាយកម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយភាពរស់រវើក ការប្រកួតប្រជែង ចីរភាព និងបរិយាបន្ន។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានអបអរសាទរចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី** ដែលត្រូវបានតែងតាំងជារដ្ឋមន្ត្រីនៃក្រសួងទេសចរណ៍កាលពីពេលថ្មីៗនេះ និងកោតសរសើរខ្ពស់ចំពោះភាពរីកចម្រើនលើនៃវិស័យទេសចរណ៍កម្ពុជាប្រកបដោយយុទ្ធសាស្ត្រ ចក្ខុវិស័យ និងការយកចិត្តទុកដាក់ខ្ពស់លើវិស័យនេះពីរាជរដ្ឋាភិបាលកម្ពុជា។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏បានលើកឡើងពីទំនាក់ទំនងជាប្រវត្តិសាស្ត្រ ទាំងនយោបាយ សង្គម-សេដ្ឋកិច្ច និងវប្បធម៌ល្អរវាងកម្ពុជា និងបារាំង។ កន្លងមកប្រទេសបារាំង បាននឹងកំពុងគាំទ្រយ៉ាងសកម្មដល់ការថែរក្សា អភិរក្ស និងការពារសម្បត្តិវប្បធម៌-

បេតិកភណ្ឌក្នុងនាមជាសហប្រធាន ICC Angkor ។ ឆ្លៀតក្នុងរំលឹកពីគុណឧបការៈរបស់ **សម្តេចវិបុលបញ្ញា សុខ អាន** ដែលជាឥស្សរជនជាន់ខ្ពស់មួយរូបមានស្នាដៃក្នុងការចូលរួមចំណែកអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរកន្លងតាមរយៈការបង្កើត ICC-Angkor និង អាជ្ញាធរអប្សរាជាដើម។ ហើយ លើសពីនេះ AFD បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងវិស័យទេសចរណ៍កម្ពុជាតាមរយៈការបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ កម្មវិធីពង្រឹងសមត្ថភាពពាណិជ្ជកម្មក្នុងវិស័យទេសចរណ៍កម្ពុជា។ រដ្ឋាភិបាលបារាំងតែងតែលើកទឹកចិត្ត និងគាំទ្រឲ្យក្រុមហ៊ុនក៏ដូចជាអង្គការបារាំងចូលរួមជួយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា ពិសេស វិស័យទេសចរណ៍គឺមានក្រុមហ៊ុនទេសចរណ៍ និងបដិសណ្ឋារកិច្ចបារាំងជាច្រើនកំពុងរកស៊ីនៅកម្ពុជា និងមានអង្គការបារាំងជួយបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

ជាចុងបញ្ចប់ **ឯកឧត្តមរដ្ឋមន្ត្រី** និង **ឯកឧត្តមអគ្គរដ្ឋទូត** បានប្តេជ្ញាបន្តពង្រឹង និងបង្កើនកិច្ចសហប្រតិបត្តិការល្អក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ការអភិរក្ស និងថែរក្សាវប្បធម៌-បេតិកភណ្ឌ ការជំរុញវិនិយោគអភិវឌ្ឍផលិតផលទេសចរណ៍ និងការជួយផ្សព្វផ្សាយគោលដៅទេសចរណ៍កម្ពុជាដល់ទីផ្សារបារាំង និងអឺរ៉ុប សំដៅអភិវឌ្ឍវិស័យទេសចរណ៍ និងទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ។